អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ការព្យាបាលរោគផ្លូវចិត្ត (ត)

website ៖ www.hoksavann.org

ថ្ងៃទី២១ មករា ២០០៩



អត្ថបទមុន យើងបានរៀបរាប់អំពីព្រះពុទ្ធជាម្ចាស់បានប្រោសនាងបដាចា ដែលកំពុងមានទុក្ខព្រួយអំពីស្វាមីបុត្រទាំងពីរ និងមាតាបិតាដែលស្លាប់បាត់បង់ជីវិតទៅ ។ ព្រះអង្គបានពន្យល់នាងឲ្យដកចិត្តចេញពីជនទាំងនោះតទៅទៀតថា បើនាងយំទួញសោកស្តាយជនទាំងនោះ ជាការឥតប្រយោជន៍ ព្រោះជនទាំងនោះពុំអាចរស់ឡើងវិញបានផង ហើយធ្វើឲ្យរូបកាយរបស់នាងទ្រុឌទ្រោមទៅដោយសារចិត្តក្រៀមក្រំផង ដូច្នេះចូរនាងមានចិត្តជាឧបេក្ខាពិចារ-ណាកម្មផលរបស់សត្វ ដែលតែងតែកើតមានយ៉ាងនេះឯង ។

បន្ទាប់ពីបានស្តាប់ធម៌ទេសនាពន្យល់អំពីហេតុដែលនាំឲ្យនាងមានទុក្ខ និងមធ្យោបាយចេញចាកទុក្ខមក នាងបានយល់ច្បាស់ហាក់ដូចជាទីងងឹតហើយគេយកប្រទីបទៅបំភ្លឺ ។ ការក្រៀមក្រំចិត្តបានធូរស្រាលបន្តិចម្តងៗ ហាក់ដូចជាគេដកសដែលមានពិសចេញពីខ្លួននាង ។ នាងមានកម្លាំងកាយកម្លាំងចិត្តឡើងវិញទោះបីនាងត្រូវអត់អាហារ អត់ដំណេកជាច្រើនថ្ងៃមកហើយក៏ដោយ ហាក់ដូចជាត្រូវថ្នាំលើកកម្លាំង ដែលគ្រូពេទ្យយ៉ាងជំនាញទៅចាក់ឲ្យនាង ។ នាងមានសេចក្តីអៀនខ្មាស់ដោយសំលៀកបំពាក់ពុំសមរម្យ ស្បែកឡើងសម្បុរអាក្រក់ដោយសារតែសេចក្តីទុក្ខក្រៀមក្រំអស់ជាច្រើនថ្ងៃ ដែលផ្ទុយពីនាងកាលនៅជាកុមារី នាងមានរូបឆោមលោមពណ៌ស្រស់បស់ល្អស្អាត ជាបុត្រគ្រួសារអ្នកមានស្តុកស្តម្ភម្នាក់ ។ ជាថ្មីទៀត នាងបដាចាបានលើកដៃទាំងពីរថ្វាយបង្គំព្រះពុទ្ធជា

ម្ចាស់ ដោយសេចក្ដីគោរពយ៉ាងជ្រាលជ្រៅបំផុត ហើយក្រាបទូលព្រះអង្គដោយក្ដីរំភើបរីករាយរបស់ខ្លួនថា បពិត្រព្រះពុទ្ធបរមគ្រូជាកំពូលនៃអ្នកប្រាជ្ញ ចិត្តរបស់ខ្ញុំព្រះអង្គបានជាសះស្បើយពីសេចក្ដីទុក្ខក្រៀមក្រំនោះហើយ ដោយឱសថគឺព្រះធម៌របស់ព្រះអង្គ ។ ខ្ញុំព្រះអង្គយល់ច្បាស់ថា ព្រះអង្គជាព្រះពុទ្ធរបស់មនុស្សលោក ត្រាស់ដឹងឡើងដើម្បីប្រយោជន៍ដល់មនុស្សលោក ព្រះអង្គជាវេជ្ជបណ្ឌិតយ៉ាងជំនាញក្នុងការព្យាបាលរោគផ្លូវចិត្តរបស់មនុស្សសត្វ ដូចជាខ្ញុំព្រះអង្គនេះឲ្យជាសះស្បើយ បើពួកគេសុខចិត្តប្រតិបត្តិតាមការណែនាំរបស់ព្រះអង្គ ។ ខ្ញុំព្រះអង្គសូមថ្វាយខ្លួនចំពោះព្រះពុទ្ធជាម្ចាស់ សូមយកព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាទីពឹងទីរលឹកចាប់ពីពេលនេះតទៅ ។ ឆ្លងតាមការពិសោធន៍របស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមានការនឿយណាយក្នុងសម្បត្តិលោកិយ៍ សូមព្រះអង្គមេត្តាអនុញ្ញាតឲ្យខ្ញុំព្រះអង្គបានបួសជាភិក្ខុនី ដើម្បីប្រតិបត្តិធម៌ឲ្យដល់នូវទីបំផុតនៃសេចក្ដីទុក្ខ ។ តាមសេចក្ដីដំណាលក្នុងរឿងនេះថា នាងបដាចាបានត្រូវអនុញ្ញាតឲ្យបួសជាភិក្ខុនី ហើយខំប្រតិបត្តិធម៌រហូតបានសំរេចជាព្រះអរហត្តផលកាត់ផ្ដាច់នូវកិលេសតណ្ហាមាននាមថា បដាចាថេរី ។

រឿងនេះបញ្ជាក់ថា នាងបដាចាដែលកើតទុក្ខនេះ ពុំមែនទុក្ខដោយមានជម្ងឺផ្លូវកាយទេ គឺកើតទុក្ខតាមផ្លូវចិត្ត ដោយសោកស្ដាយចំពោះជនដែលជាទីស្រឡាញ់របស់ខ្លួនបានស្លាប់បាត់បង់ជីវិតទៅ ។ បើមិនបានជួបព្រះពុទ្ធទេ នាងនឹងត្រូវស្លាប់បាត់បង់ជីវិតក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខ ដោយការព្រួយចិត្តខ្លាំងអត់អាហារអត់ដេកនាំឲ្យសរីរៈរាងកាយមានជម្ងឺ ។ កាយនិងចិត្តមានសម្ពន្ធភាពទាក់ទងគ្នា កាលណាព្រួយចិត្តវាជះឥទ្ធិពលទៅលើផ្លូវកាយ ព្រោះការគិតរវើរវាយគ្មានសម្រាក នាំឲ្យរញ្ជួយដល់អាការៈរាងកាយ ដូចជាបេះដូងដើរខុសប្រក្រតីទៅជាកើតជម្ងឺ ។ ជម្ងឺរបស់នាងបដាចាជាជម្ងឺផ្លូវចិត្ត ពុំមែនជាជម្ងឺផ្លូវកាយទេ ប៉ុន្តែបើទុកឲ្យយូរនឹងកើតជម្ងឺផ្លូវកាយថែមទៀត ជាកុសលល្អនាងបានជួបព្រះពុទ្ធ បានដោះស្រាយវិបត្តិផ្លូវចិត្តនេះឲ្យជាសះស្បើយ នាងមិនទាន់កើតជម្ងឺផ្លូវកាយនៅឡើយ គ្រាន់តែហេវហត់អស់កម្លាំងប៉ុណ្ណោះ ។ បើមិនចេះរបៀបដោះស្រាយ គេបញ្ជូននាងទៅមន្ទីរពេទ្យដើម្បីពិគ្រោះជម្ងឺផ្លូវកាយ ទោះបីវេជ្ជបណ្ឌិតមានជំនាញដ៏ខ្ពស់ក៏ដោយ ក៏មិនអាចមើលជម្ងឺនាងឲ្យជាសះស្បើយឡើ

យ បើគេមិនដោះស្រាយវិបត្តិផ្លូវចិត្តរបស់នាងទេ ។ វេជ្ជបណ្ឌិតអាចព្យាបាលរោគផ្លូវកាយ បើការកើតទុក្ខរបស់នាងនាំឲ្យមានជម្ងឺដល់ផ្លូវកាយ ។

ជម្ងឺផ្លូវកាយប្រភេទខ្លះមកអំពីការព្រួយចិត្ត ដូច្នេះវេជ្ជបណ្ឌិតបើពិនិត្យមើលអាការៈក្នុងខ្លួនអ្នកទៅពិគ្រោះជម្ងឺ ឃើញនៅល្អទាំងអស់ ប៉ុន្តែអ្នកជម្ងឺប្រាប់គ្រូពេទ្យថា ខ្ញុំឈឺនេះឈឺនោះ ដូចពោលថា ខ្ញុំឈឺក្បាលណាស់ជាដើម ។ ជួនកាលការឈឺក្បាលបណ្ដាលមកពីការគិតច្រើន ដោយពិបាកចិត្តនឹងរឿងអ្វីមួយ ។ ការគិតច្រើនគ្មានសម្រាក ធ្វើឲ្យចលនាសរសៃប្រសាទ ក៏ខំប្រឹងធ្វើការខ្លាំងខុសប្រក្រតីទៅជាឈឺក្បាល ។ បើគេទៅសម្រាកឈប់គិតឈប់ព្រួយចិត្ត ការឈឺក្បាលនោះក៏បាត់ទៅឯង នេះផ្លូវចិត្តឲ្យឥទ្ធិពលមកលើផ្លូវកាយ ។

ដូចហេតុផលដូចពោលមកនេះ វេជ្ជបណ្ឌិតគួរសួរប្រវត្តិរបស់អ្នកជម្ងឺ ដើម្បីរកហេតុដែលនាំឲ្យមានជម្ងឺ បើពិនិត្យផ្លូវកាយគ្មានឃើញកើតរោគអ្វីទេ ។ ពុទ្ធសាសនាពោលថា ចិត្តជាធម្មជាតិមានកម្លាំងមានឥទ្ធិពលខ្លាំងណាស់មកលើផ្លូវកាយ ។ ឧទាហរណ៍ បុគ្គលម្នាក់ត្រូវពស់ចឹក បើបុគ្គលនោះពុំទាន់ដឹងថា ពស់ដែលចឹកនោះមានពិសទេ បុគ្គលនោះនៅមានស្មារតីនិយាយបានដើរបាន ប៉ុន្តែបើដឹងថាពស់ដែលចឹកនោះជាពស់មានពិស បុគ្គលនោះទៅជាសន្លប់ក៏មាន ។ ដូចគ្នានឹងអ្នកដែលត្រូវគ្រាប់កាំភ្លើង បើមិនទាន់ឃើញឈាមទេ បុគ្គលនោះនៅដើរបាន លុះពេលឃើញឈាម បុគ្គលនោះដួលសន្លប់ភ្លាម ដែលខ្មែរហៅថាកំរោលគ្រុបនោះឯង ។ ហេតុអ្វីបានជាសន្លប់ ? បានជាសន្លប់ព្រោះបុគ្គលនោះភ័យតក់ស្លុតមានចិត្តធ្លាក់ចុះអស់សង្ឃឹមដោយយល់ថា បើពស់ចឹកឬត្រូវគ្រាប់កាំភ្លើងកម្រមានជីវិតរស់ណាស់ ។ ការភិតភ័យនេះ នាំឲ្យចលនាបេះដូងដើរញាប់ខុសធម្មតា របូតដល់គាំងក៏មាន ។ សភាពការណ៍នេះកើតឡើងដោយចិត្តមានឥទ្ធិពលទៅលើផ្លូវកាយ ។

(នៅមានត)